# តើយើងអាចរំពឹងអ្វីពីព្រះជាម្ចាស់នៅពេលនេះ ?
# ( តែងសេចក្តី ទី៣ ក្នុងចំណោម តែងសេចក្តីចំនួន៧ )

**សេចក្តីពិតខាងវិញ្ញាណ ទី៣៖ ចូររំពឹងថាព្រះទ្រង់ជួយពង្រឹងជំនឿរបស់អ្នក ស្អាងចរិតលក្ខណៈរបស់អ្នក និង ស្តារសេចក្តីសង្ឃឹមរបស់អ្នកដោយសេចក្តីស្រឡាញ់ តាមរយៈការរងទុក្ខ**



អ្ហាហ៍! តើពេលណាទើបខ្ញុំអាចចេញពីផ្ទះនេះបាន? តើដល់ពេលណា ទើបជីវិតត្រឡប់ទៅរកសភាពធម្មតាវិញ?

បច្ចុប្បន្ននេះ ជនជាតិអាមេរិកាំងប្រមាណជា៩៥% ត្រូវបានតម្រូវឲ្យស្នាក់នៅក្នុងផ្ទះ។ ទូទាំងសកលលោក មនុស្សរាប់ពាន់លាននាក់ កំពុងស្ថិតនៅក្នុងការរាំងខ្ទប់មិនឲ្យចេញក្រៅ តាមរូបភាពខុសៗគ្នា។ សម្រាប់មនុស្សខ្លះ ការនោះមិនមានបញ្ហាអ្វីទេ។ សម្រាប់មនុស្សភាគច្រើន ទោះបីពួកគេស្វាគមន៍ការសម្រាកដ៏ល្អ ពីជីវិតធម្មតារបស់ពួកគេក៏ដោយ ក៏ពួកគេកំពុងអារម្មណ៍ថា កាន់តែតានតឹងឡើងៗ ខណៈពេលដែលវិបត្តិចេះតែបន្ត ដោយមិនមើលមិនឃើញថានឹងត្រូវបញ្ចប់នៅពេលណានៅឡើយ។ ក្រោយដែលបានរស់នៅអស់រយៈពេលរាប់សប្តាហ៍ ដោយមិនបានចេញទៅណា ២៤/៧ បាត់បង់ការងារ ភ័យខ្លាចថាតើនឹងមានអ្វីកើតឡើងខាងមុខទៀត សម្ពាធកាន់តែគរឡើងដូចភ្នំ។ សប្តាហ៍មុនមានការតវ៉ាជាច្រើន បានចាប់ផ្តើមផ្ទុះឡើង។ ប្រជាជនបានប្រមូលផ្តុំគ្នាតាមផ្លូវ។ មនុស្សដែលបានឆ្លងជំងឺនេះ បានកើនឡើងដល់ ២.៥លាន នាក់ (ត្រូវបានបញ្ជាក់) ហើយមានការស្លាប់រហូតដល់ ១៦០ ០០០នាក់ គ្រាន់តែក្នុងរយៈពេលពីរបីខែនេះប៉ុណ្ណោះ។

ក្នុងពេលវេលាបែបនេះ តើគ្រីស្ទបរិស័ទត្រូវគិតដូចម្តេច ត្រូវមានអារម្មណ៍បែបណា ហើយត្រូវធ្វើអ្វីដែរ?

ស្ថិតក្រោមកាលៈទេសៈខុសគ្នា តែមានការលំបាកដូចគ្នា (ដូចជា ត្រូវគេវាយ ត្រូវលិចសំពៅ ត្រូវជាប់គុក) លោកសាវ័កប៉ុលប្រើពាក្យដ៏ល្បីក្នុងប្រសាសន៍របស់លោកថា "ឥឡូវនេះ នៅមានសេចក្តីជំនឿ សេចក្តីសង្ឃឹម និងសេចក្តីស្រឡាញ់ ទាំង៣មុខនេះ តែសេចក្តីដែលវិសេសជាងគេ គឺជាសេចក្តីស្រឡាញ់" (១កូរិនថូស ១៣:១៣)។ ដូច្នេះ តើសព្វថ្ងៃនេះ សេចក្តីជំនឿមានលក្ខណៈដូចម្តេច? តើយើងអាចរកបានសេចក្តីសង្ឃឹមពីណា? តើឯណាទៅសេចក្តីស្រឡាញ់?

នៅពេលដែលខ្ញុំសម្លឹងមើលជុំវិញ ខ្ញុំមានការដឹងគុណចំពោះអ្នកដែលអនុវត្តវិធានការផ្ទាល់ ក្នុងចំណោមពួកយើងទាំងអស់គ្នា។ វីរភាព និងការលះបង់ពីសំណាក់វេជ្ជបណ្ឌិត ក្រុមការងារវេជ្ជសាស្ត្រ អ្នកស្រាវជ្រាវ និងមន្ត្រីសាធារណៈផ្សេងទៀត ដែលអ្នកខ្លះតស៊ូប្រថុយជីវិតផ្ទាល់ខ្លួន ដើម្បីជួយដល់ជីវិតអ្នកដទៃ គឺពិតជាការបន្ទាបខ្លួន និងជា

ការប៉ះពាល់ចិត្តជាទីបំផុត។ លើសពីនោះទៅទៀត ការទាក់ទាញចំណាប់អារម្មណ៍ ប្រកបដោយភាពច្នៃប្រឌិត ពីសំណាក់ក្រុមសិល្បករ-ការនី តន្រ្តីករ និងក្រុមករី ទឹកចិត្តក្លួលអាណិត និងទឹកចិត្តសុប្បុរសធម៌ ទាំងអ្នកមាន និងអ្នកក្រ ហើយភាពចិត្តល្អ និងការឈឺឆ្អាលពីសំណាក់បុគ្គលឯកជនជាច្រើន ពិតជាកម្សាន្តចិត្ត ថែមទាំងលើកទឹកចិត្តដល់ខ្ញុំណាស់។

បន្ទាប់មក មានមនុស្សដែលគិតបែបវិជ្ជមាន ជាអ្នកដែលច្រានចោលការជាប់ឃុំឃាំងក្នុងចិត្តគំនិតរបស់ខ្លួនឯងឡើយ ទោះបោជារូបកាយរបស់ពួកគេ ត្រូវជាប់ឃុំនៅក្នុងផ្ទះសិនក៏ដោយ។ ក្រុមមនុស្សសុទិដ្ឋិនិយម ដែលជួយកំឡាទឹកចិត្តទាំងនេះ គឺជាអ្នកដែលមើលឃើញឱកាសនៅគ្រប់ទីកន្លែង ព្រមទាំងទាញយកប្រយោជន៍ចេញពីឱកាសទាំងនោះ ដូចជា ការមានពេលវេលាកាន់តែច្រើនជាមួយគ្រួសារ មានការដកឃ្លាសម្រាប់ភាពច្នៃប្រឌិត និងតន្រ្តី មានភាពស្ងៀមស្ងាត់ និងការសម្រាក មានពេលអាន និងឆ្លុះបញ្ចាំងច្រើន មានទំនាក់ទំនងជាមួយមិត្តភក្តិ ។ល។ ពួកគេកំពុងរៀនសូត្រនូវអ្វីដែលថ្មីៗ ហើយស្វែងរកឃើញនូវរបៀបដ៏មានអត្ថន័យ ដើម្បីបង្ហាញក្តីស្រឡាញ់ព្រះគ្រីស្ទ ទៅកាន់មនុស្សទោះនៅជិតឬឆ្ងាយ។



*ចម្លាក់ដែលពណ៌នា ការរងទុក្ខរបស់លោកយ៉ូប នៅជាប់ហោរជាងខាងជើង នៃវិមាន Chartres Cathedral, ប្រទេសបារាំង*

ទោះបីយ៉ាងណាក៏ដោយ មានហេតុផលច្រើនយ៉ាង មនុស្សគ្រប់គ្នាមិនមែនសុទ្ធតែជាអ្នកអនុវត្តវិធានការណ៍ផ្ទាល់ ឬជាអ្នកមានគំនិតវិជ្ជមានទាំងអស់គ្នាទេ។ សម្រាប់អស់អ្នកដែលរងការប៉ះទង្គិចធ្ងន់ធ្ងរពីមេរោគក្លូណា ការនៅឃុំខ្លួនឯងក្នុងផ្ទះ ឬការបិទមុខរបរអាជីវកម្ម ពួកគេមានពេញដោយការឈឺចាប់ជាទម្ងន់ មានការភ័យខ្លាច និងការខាតបង់។ អ្នកខ្លះមានអារម្មណ៍ដូចលោកយ៉ូប ដែលកូនៗទាំងប៉ុន្មានរបស់គាត់ ស្រាប់តែបានស្លាប់ភ្លាមៗទាំងអស់គ្នា រីឯសុខភាពរបស់គាត់វិញក៏ស្រាប់តែត្រូវបានបំផ្លាញទាំងស្រុង។ អ្វីដែលគាត់អាចធ្វើបាន គឺបានត្រឹមតែអង្គុយនៅដី ទាំងទួញយំ ឬអំពាវនាវទៅព្រះជាម្ចាស់ ដោយព្យាយាមរកមធ្យោបាយដោះស្រាយ ជាមួយនឹងសោកនាដកម្ម ដ៏នឹកស្មានមិនដល់។ មានមនុស្សកាន់តែច្រើនឡើង នៅទូទាំងសកលលោក កំពុងតែមានទុក្ខក្រៀមក្រំ ដោយសារការស្លាប់នៃមនុស្សជាទីស្រឡាញ់របស់ពួកគេ ឬការបិទជីវិតរស់ និងជីវភាពប្រចាំថ្ងៃរបស់ពួកគេ។ ពួកគេនៅតែរកនឹកមិនយល់ នូវគោល

បំណង និងហេតុផល នៃការឈឺចាប់របស់ពួកគេឡើយ។ ពួកគេមិនដឹងថាតើអ្វីដែលប៉ះទង្គិចពួកគេ ឬក៏មិនដឹងថាត្រូវទៅឯណាវិញដែរ។

ប្រសិនបើអ្នកកំពុងមានអារម្មណ៍បែបនេះ សូមជ្រាបថា ជួនកាល ពេលស្ថិតក្នុងការឈឺចាប់ យើងមិនងើបមុខឡើង ហើយចៀសមិនផុតពីទុក្ខព្រួយ និងភាពអស់សង្ឃឹមនោះទេ។ ជួនកាល យើងមិនអាចសង្ឃឹមអ្វីសោះ ទោះជាយើងខិតខំធ្វើខ្លួនជាមនុស្ស ដែលមានគំនិតវិជ្ជមានយ៉ាងណាក៏ដោយ។ ហើយ អញ្ចឹងក៏មិនអីដែរ។ ការមានជំនឿលើព្រះ មិនមែនតែងតែស្វាហាប់ និងមានស្ថេរភាពខាងផ្លូវអារម្មណ៍ជានិច្ចនោះទេ។ ការមានជំនឿដល់ព្រះ មិនមែនសម្រាប់តែអ្នកអនុវត្តវិធានការណ៍ និងអ្នកមានគំនិតវិជ្ជមានទេ។ សេចក្តីជំនឿរួមបញ្ចូលទាំងការទុកចិត្តថា ព្រះទ្រង់នៅតែបីទ្រអ្នក ទោះបីនៅពេលដែលអ្នកមានអារម្មណ៍មិនសូវខ្លាំង ឬធនធានចាំបាច់ដើម្បីតោងជាប់តាមទ្រង់ក្តី។

ប៉ុន្តែ យើងនៅមានសង្ឃឹម។

**សេចក្តីពិតខាងវិញ្ញាណ ទី៣៖** ចូររំពឹងថា ព្រះរបស់អ្នក ទ្រង់ប្រកបដោយសេចក្តីស្រឡាញ់ ទ្រង់នឹងពង្រឹងជំនឿរបស់អ្នក ស្អាងចរិតលក្ខណៈរបស់អ្នក និងស្តារសេចក្តីសង្ឃឹមរបស់អ្នក តាមរយៈការឈឺចាប់របស់អ្នក។ (រ៉ូម ៥:៣-៥; ៨:២៨-២៩; ២កូរិនថូស ១:៨-៩; បរិទេវ ៣:២២-២៤)

នៅក្នុងកណ្ឌព្រះគម្ពីរ រ៉ូម លោកប៉ុលមិនបានផ្តល់ការពន្យល់ ឬការការពាររបស់ព្រះ ស្តីពីការឈឺចាប់របស់មនុស្សទេ ក៏ប៉ុន្តែ លោកផ្តោតសំខាន់លើរបៀបដែលព្រះដ៏ពេញដោយក្តីស្រឡាញ់ ធ្វើការតាមរយៈការឈឺចាប់របស់មនុស្ស សម្រាប់ជាសេចក្តីល្អដល់ពួកគេ។ លោកបានថ្លែងថា៖

> មិនតែប៉ុណ្ណោះសោត យើងនៅតែអួតក្នុងកាលដែលមានទុក្ខលំបាកដែរ ដោយដឹងថា សេចក្តីទុក្ខលំបាកបង្កើតឲ្យមានសេចក្តីទ្រាំទ្រ សេចក្តីទ្រាំទ្របង្កើតឲ្យមានសេចក្តីសុំាថ្មីក សេចក្តីសុំាថ្មីកបង្កើតឲ្យមានសេចក្តីសង្ឃឹម។ ឯសេចក្តីសង្ឃឹមក៏មិនដែលនាំឲ្យយើងមានសេចក្តីខ្មាសឡើយ ពីព្រោះសេចក្តីស្រឡាញ់របស់ព្រះ បានផ្សាយមកសព្វក្នុងចិត្តយើងរាល់គ្នា ដោយសារព្រះវិញ្ញាណបរិសុទ្ធ ដែលព្រះបានប្រទានមកយើងហើយ។
>
> រ៉ូម ៥:៣-៥

លោកប៉ុលបានដឹងយ៉ាងច្បាស់ថា នៅពេលពួកយើងណាម្នាក់ឈឺចាប់ យើងងាយធ្វើឲ្យខ្លួនយើង ពង្រីកដែនកំណត់ទាំងខាងផ្លូវកាយ និងផ្លូវអារម្មណ៍របស់យើង។ យើងអាចនឹងឈោងចាប់ជំនួយមកពីព្រះ ប៉ុន្តែ នៅពេលដែលយើងមិនទទួលបានការប្រោសឲ្យជា ឬការឈឺចាប់របស់យើងនៅតែអូសបន្លាយ យើងប្រហែលអស់សង្ឃឹម ស្លន់ស្លោរ ឬក៏ចង់បោះបង់ចោលជំនឿចំពោះព្រះ។ ប៉ុន្តែ នេះគ្រាន់តែជាចំណុចធ្លាក់ចុះទាបបំផុត ដែលពួកយើងភាគច្រើន ត្រូវបានព្រះធ្វើឲ្យភ្ញាក់ផ្អើល។ យើងអាចនឹងប្រែជាមានអារម្មណ៍ថាមានសន្តិភាពដោយមិនរំពឹងទុកវិញ។ យើងក៏ប្រហែលជាស្រាប់តែមានអារម្មណ៍ដឹងសេចក្តីស្រឡាញ់របស់ទ្រង់ តាមរយៈក្តីសប្បុរសពីអស់អ្នកដែលនៅជុំវិញខ្លួនយើង។ យើងអាចនឹងរកបាននូវការជំរុញទឹកចិត្ត និងកម្លាំងថ្មីបន្ថែមទៀត ដើម្បីដល់ទីបញ្ចប់ អ្នកអាចលះបង់ចោលនូវអំពើបាប ដែលធ្លាប់បានត្រួតត្រាលើជីវិតរបស់អ្នក។ អ្នកអាចនឹងមើលឃើញភាពស្រស់បំព្រងដោយមិនបានរំពឹងទុក ដែលមាននៅក្នុងអ្វីមួយ ឬនរណាម្នាក់ ខណៈពេលដែលអ្នកបានបាត់បង់ក្តីសង្ឃឹម ថាមិនដឹងជាអាចមានអារម្មណ៍បែបនោះម្តងវិញឬទេ។

តាមរយៈការប៉ះពាល់របស់ព្រះ ដ៏គួរឲ្យភ្ញាក់ផ្អើលបែបនេះ ជំនឿរបស់យើងចំពោះព្រះអង្គ បញ្ចេះសារជាថ្មីឡើងវិញ។ សមត្ថភាពរបស់យើងក្នុងការអត់ធ្មត់ទ្រាំទ្រដោយស្មោះត្រង់ ទោះស្ថិតក្នុងពេលរងទុក្ខ ក៏កាន់តែកើនឡើងជានិច្ច។ ការដែលយើងបានជួបពិសោធនូវសេចក្តីល្អមកពីព្រះ ជួយបន្សុទ្ធ ហើយចម្រើនចរិតលក្ខណៈរបស់យើង ឲ្យកាន់តែមាន

ក្រមសីលធម៌ខ្ពស់។ ជីវិតរស់នៅខាងវិញ្ញាណរបស់យើង ត្រូវបានកែជាថ្មីឡើងជាដរាប។ យើងជ្រាបច្បាស់ពីសេចក្តីស្រឡាញ់របស់ព្រះ សម្រាប់យើង តាមរបៀបមួយថ្មី។ យើងមើលឃើញសេចក្តីស្រឡាញ់នៃព្រះគ្រីស្ទ ត្រូវបានបង្ហាញចេញតាមរយៈជីវិតរបស់យើង ហើយយើងមានអារម្មណ៍រស់នៅ ដោយមានគោលបំណង មានអត្ថន័យ និងមានអំណរ។ សេចក្តីសង្ឃឹមស្រាប់តែផុសចេញមកពីខាងក្នុងខ្លួនយើងសារជាថ្មីម្តងទៀតក្នុងពេលនេះ មិនមែនដោយព្រោះតែយើងទទួលបានការប្រោសឲ្យជាជំងឺ ឬត្រូវបានប្រោសឲ្យរួចផុតពីបញ្ហាទេ ប៉ុន្តែគឺពោះតែព្រះវិញ្ញាណបរិសុទ្ធ បានបើកភ្នែករបស់យើង ឲ្យឃើញព្រះវត្តមាននៃព្រះ ដែលប្រកបដោយសេចក្តីស្រឡាញ់ និងការយកប្រះហឫទ័យទុកដាក់ខ្ពស់ ខណៈដែលយើងកំពុងស្ថិតកាលៈទេសៈបែបនេះ។ នៅចំពេលដែលយើងរៀបនឹងបោះបង់ចោល ឬក៏បានបោះបង់ចោលរួចទៅហើយក្តី ព្រះទ្រង់បានមកប៉ះពាល់យើង។

កាលណាដែលព្រះវិញ្ញាណបរិសុទ្ធធ្វើការនៅក្នុងជីវិតរបស់អ្នក នៅពេលដែលកំពុងស្ថិតក្នុងការឈឺចាប់ នោះយើងនឹងដឹងច្បាស់ថា ព្រះទ្រង់មិនដែលបោះបង់យើងចោលឡើង។ យើងនៅតែមានទីន្លែងដែលត្រូវទៅ និងមានអ្នកដែលជាទីពឹង នៅពេលដែលស្ថិតនៅពេលវេលាដែលងងឹតសូន្យឈឹង។ យើងអាចយំយែក ស្រែកថ្ងូរ ហើយលន់តួរអំពើបាបរបស់យើង ដោយចិត្តខ្ទេចខ្ទាំ ឬក៏គ្រាន់តែបន្ទំលាក់ទុកដោយការកើតទុក្ខ ដូចជាអ៊ីស្រាអែលបានជួបប្រទះ បន្ទាប់ពីការដែលព្រះវិហារដំបូងនៅទីក្រុងយេរូសាឡិម ត្រូវបានបំផ្លិចបំផ្លាញចោល (ឆ្នាំ ៥៨៦ មុនគស) តាមផ្លូវដែលត្រូវគេដឹកនាំទៅធ្វើជាឈ្លើយសឹក នៅឯស្រុកបាប៊ីឡូន។ ក៏ប៉ុន្តែ ទោះយ៉ាងនោះក្តី យើងនឹងឈានដល់ដំណាក់កាលមួយ ដែលយើងក៏អាចនិយាយដូចលោកហោរាយេរេមាដែរថា៖

កុំតែមានសេចក្តីសប្បុរសរបស់ព្រះយេហូវ៉ា នោះយើងបានសូន្យបាត់អស់រលីងទៅហើយ ឯសេចក្តីមេត្តាករុណារបស់ទ្រង់ នោះមិនចេះផុតឡើយ សេចក្តីទាំងនោះ ចេះតែថ្មីឡើងរាល់តែព្រឹកជានិច្ច សេចក្តីស្មោះត្រង់របស់ទ្រង់ធំណាស់។ ព្រលឹងខ្ញុំបានពោលថា “ព្រះយេហូវ៉ាជាចំណែកនៃខ្ញុំ ហេតុនោះខ្ញុំនឹងសង្ឃឹមដល់ទ្រង់”។

បរិទេវ ៣:២២-២៤



*នាងម៉ារា និងយ៉ូហាន កើតទុក្ខឈឺចាប់ នៅពេលដែលព្រះសពរបស់ព្រះយេស៊ូវ ត្រូវបានដាក់ចុះពីលើឈើឆ្កាង*

*មេរៀនសម្រាប់ការអនុវត្តខាងវិញ្ញាណ*

តើអ្នកកំពុងឆ្លងកាត់បទពិសោធន៍នៃការបាត់បង់ដ៏ហួលប្រមាណ ភាពអស់សង្ឃឹម ឬការភ័យខ្លាច នៅពេលឥឡូវនេះមែនទេ? ឬក៏ ប្រសិនមិនមែនអ្នកទេ នោះក៏ប្រាកដជាមានអ្នកណាម្នាក់ ដែលអ្នកកំពុងរស់នៅជាមួយ ឬអ្នកណាដែលអ្នកខ្វល់ខ្វាយពីគាត់ ដែលកំពុងឆ្លងកាត់បទពិសោធន៍នេះដែរ។ ប្រសិនបើដូច្នោះមែន នេះមិនមែនជាទីកន្លែងងាយស្រួលនៅទេ។ ប៉ុន្តែ នៅមានសង្ឃឹម។ មានការពិតធំជាងអ្វីដែលអ្នកកំពុងយល់ដឹង ហើយឆ្លងកាត់ នៅខណៈពេលនេះ។ ព្រះទ្រង់ប្រហែលជាមិនសព្វព្រះហឫទ័យដោះអ្នកឲ្យរួច ពីអស់ទាំងបញ្ហា និងការឈឺចាប់របស់អ្នកទេ ប៉ុន្តែ នោះមិនមែនមានន័យថា ព្រះអង្គគ្មានអ្វីជាប់ពាក់ព័ន្ធនោះឡើយ។ ផ្ទុយទៅវិញ គឺស្ថិតនៅក្នុងភាពអស់កម្លាំង និងភាពអស់សង្ឃឹមហ្នឹងហើយ ដែលព្រះអង្គអាចបង្កើតឲ្យមាន ការល្អនៅក្នុងជីវិតរបស់អ្នក ដែលនៅក្នុងកាលៈទេសៈខុសពីនេះ អ្នកមិនអាចកើតចេញជាលទ្ធផលបែបនេះបានទេ។

នៅក្នុងបរិបទដែលកំពុងនិយាយអំពីការរងទុក្ខលំបាករបស់មនុស្ស និងការត្អូញត្អែរទាំងដំងូររបស់មនុស្ស ហើយជួនកាល យើងមិនដឹងសូម្បីតែត្រូវអធិស្ឋានយ៉ាងម៉េចផង លោកសាវ័កប៉ុល ផ្តល់មកនូវពាក្យ ប្រកបដោយការយល់ដឹង និងសេចក្តីសង្ឃឹមថា៖

តែយើងដឹងថា គ្រប់ការទាំងអស់ផ្សំគ្នា សំរាប់សេចក្ដីល្អដល់ពួកអ្នកដែលស្រឡាញ់ព្រះ គឺដល់ពួកអ្នកដែលទ្រង់ហៅមកតាមព្រះដំរិះទ្រង់។ ដ្បិតអ្នកណាដែលទ្រង់បានស្គាល់ជាមុន នោះទ្រង់ក៏តម្រូវទុកជាមុន ឲ្យបានត្រឡប់ដូចជារូបអង្គនៃព្រះរាជបុត្រាទ្រង់ ដើម្បីឲ្យព្រះរាជបុត្រាបានធ្វើជាបងច្បងគេក្នុងពួកបងប្អូនជាច្រើន។<br>រ៉ូម ៨:២៨-២៩

ហើយចុះ ព្រះអង្គដែលទ្រង់ល្អដូច្នេះ តើទ្រង់កំពុងមានអ្វីនៅក្នុងរាជគំនិតរបស់ទ្រង់ទ?

"ការល្អ"មិនចាំបាច់ទាល់តែ ប្រោសឲ្យអ្នកជាជំងឺ ភាពចម្រុងចម្រើន ឬអ្វីៗផ្សេងទៀត ដែលអ្នកកំពុងទូលសូមក្នុងពេលនៃភាពអស់សង្ឃឹមរបស់អ្នកឡើយ។ ការល្អបំផុត ដែលព្រះទ្រង់បង្កើតតាមរយៈការឈឺចាប់របស់អ្នក ធ្វើឲ្យអ្នកកាន់តែដូចព្រះយេស៊ូវគ្រីស្ទឡើងថែមទៀត ដែលទ្រង់ជាព្រះរាជបុត្រានៃព្រះពិត គឺឲ្យអ្នកកាន់តែមានពេញដោយសេចក្តីជំនឿ សង្ឃឹម និងសេចក្តីស្រឡាញ់។

បំណងប្រាថ្នាធំបំផុតរបស់អ្នក ប្រហែលមានតែចង់ទទួលបានភាពធូរស្រាល ចេញពីការឈឺចាប់របស់ ឬចង់ទទួលបានការអស្ចារ្យបែបណាមួយ នៅក្នុងជីវិតរបស់អ្នក។ ជីវិតខ្ញុំតែងតែជួបនឹងការអស្ចារ្យ។ ប៉ុន្តែ ពួកយើងគ្មានអ្នកណាម្នាក់ដឹងថា ព្រះទ្រង់នឹងធ្វើអ្វី ឬនឹងមិនធ្វើអ្វីនោះទេ។ តើអ្នកសុខចិត្តរស់នៅ ជាមួយនឹងអ្វីដែលមិនច្បាស់លាស់ ប៉ុន្តែនឹងមិនដែលបោះបង់ចោល នូវក្តីរំពឹងថាទ្រង់នឹងធ្វើការ តាមរយៈការឈឺចាប់របស់អ្នក ឲ្យបានត្រឡប់ទៅជាការល្អ យោងតាមអ្វីដែលជាអាទិភាព និងការឲ្យតម្លៃរបស់ទ្រង់វិញ? នេះគឺជាសេចក្តីជំនឿរបស់យើង។ នេះគឺជាសេចក្តីសង្ឃឹមរបស់យើង។

កម្រងសំណេរតែងសេចក្តី "តើយើងអាចរំពឹងអ្វីពីព្រះនៅពេលឥឡូវនេះ?" ត្រូវបានចងក្រងឡើង ដើម្បីជាការឆ្លើយតបទៅកាន់វិបត្តិជាសាកលឆ្នាំ២០២០ នៃជំងឺកូវីដ១៩។ សំណេរនេះផ្តោតលើរបៀបដែលអ្នកជឿអាចទុកចិត្តព្រះខ្លាំងជាងមុន ក្នុងពេលដែលជួបប្រទះនឹងបញ្ហា។ សំណេរតែងសេចក្តីនេះមានពន្យល់បន្ថែម ស្តីពីអនុសាសន៍សម្រាប់ជូនជាការអនុវត្ត ដែលបានផ្តល់ជូន នៅក្នុងជំពូកទីប្រាំបី "ការទុកចិត្តព្រះ" ក្នុងសៀវភៅដែលមានចំណងជើងថា *THE SPIRIT-LED LEADER: NINE LEADERSHIP PRACTICES AND SOUL PRINCIPLES* (HERNDON, VA: ALBAN INSTITUTE, ឆ្នាំ២០០៥), ទំព័រ ១៨៤-១៩០។